# ការយល់ដឹងអំពី
# ការគ្រប់គ្រងសំណល់



**ទំនាក់ទំនង:** អាគារ ៣A ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ១៦ ៧៣៨ ៤០៣
អ៊ីម៉ែល admin@cambodiacleancity.gov.kh គេហទំព័រ www.cambodiacleancity.gov.kh

## តើអ្នកដឹងទេ?

នៅព្រះរាជាណាចក្រកម្ពុជា គ្រាន់តែរាជធានីភ្នំពេញ មានសំណល់ជាប្រចាំថ្ងៃប្រមាណជា ១,២៧២.៤ តោន ក្នុងមួយថ្ងៃ ដែលក្នុងនោះមានសំណល់សរីរាង្គប្រមាណ ៧២,៣៨% ជាផលិតផលប្លាស្ទិក ១៥,៧៦% និងសំណល់ជាក្រដាស ៣,៤៥%។





ប្រជាពលរដ្ឋទាំងអស់មាន
តួនាទីក្នុងការគ្រប់គ្រងកាក
សំណល់ដែលពួកគាត់បាន
បញ្ចេញ ព្រោះថាសំណល់
ខ្លះអាចមានផលប៉ះពាល់ដល់
បរិស្ថាន និងសុខុមាលភាព
របស់ពួកគាត់ផ្ទាល់។

បែងចែកកាកសំណល់ទៅតាម
ប្រភេទផ្សេងៗដូចជា៖ កែវ ដប
ប្លាស្ទីក ក្រដាស និងកាក សំណល់
ដែលមានជាតិគីមីឲ្យដាច់ពីគ្នាទៅ
តាមលទ្ធភាព។





សំណល់ប្រភេទ ខ្លះជាសំណល់ដែលមាន
គ្រោះថ្នាក់ ដែលតម្រូវឲ្យមានការបែងចែក
ឱ្យបានច្បាស់លាស់។

យើងអាចកាត់បន្ថយសំណល់ទាំងនោះតាមរយៈ៖

១-ការកាត់បន្ថយបរិមាណសំណល់

២-ការប្រើប្រាស់ឡើងវិញ

៣-ការកែច្នៃ

3R




## ការកាត់បន្ថយបរិមាណសំណល់ ( Reduce )

ការគ្រប់គ្រងសំណល់ និងកែច្នៃសំណល់មានតួនាទីសំខាន់ចំពោះកិច្ចការបរិស្ថាន។ ហេតុដូច្នេះ ការបែងចែកនូវប្រភេទសំណល់ដែលអាចយកទៅប្រើប្រាស់ជាថ្មី (ដូចជា ប្លាស្ទិក ឬដប) ឬដែលអាចកែច្នៃ (ដូចជាសំណល់សរីរាង្គ និងមិនមែនសរីរាង្គ) គឺជាមធ្យោបាយដ៏ល្អប្រសើរដើម្បី កាត់បន្ថយបរិមាណសំណល់ក៏ដូចដើម្បីចូលរួមចំណែកកាត់បន្ថយផលអវិជ្ជមាននៃសកម្មភាពរបស់មនុស្សទៅលើបរិស្ថាន។

ការដាក់សំណល់ដោយគ្មានការបែងចែកជាមូល-ហេតុចំបងដែលមិនអាចកាត់បន្ថយបរិមាណរបស់សំណល់។






កាត់បន្ថយកាកសំណល់
ដោយប្រើប្រាស់សម្ភារៈ
ដាក់អីវ៉ាន់ដែលអាចធ្វើការ
ប្រើប្រាស់បានច្រើនដង
ដូចជាកែវ ឬដប។



កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទីក
ដោយអាចប្រើជាកញ្ចប់ក្រដាសក្នុង
ការដាក់អីវ៉ាន់។




មួយវិញទៀតអ្នកអាចប្រើប្រាស់ថង់បរិ-
ស្ថាន (Eco-bag) ដែលអាចជួយឲ្យអ្នក
កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទីក។

# ការប្រើប្រាស់ឡើងវិញ ( Reuse )



សំណល់ខ្លះអាច ទាញយកមកប្រើប្រាស់ឡើងវិញ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព។

អ្នកអាចធ្វើការជួសជុលគ្រឿងអេឡិចត្រូនិចចាស់ៗរបស់អ្នកមកប្រើប្រាស់ឡើងវិញដែលអាចសន្សំថវិកាបាន។






ក្រដាសកាសែត និងទស្សនាវដ្ដីចាស់ៗអាចយកមកប្រើប្រាស់ឡើងវិញបានដោយកែច្នៃវាជាវត្ថុសិល្បៈ ។

# ការកែច្នៃឡើងវិញ ( Recycle )



មានវត្ថុជាច្រើនដែលយើងបានប្រើប្រាស់ជារៀងរាល់ថ្ងៃ ដូចជាក្រដាស ដប ដ័រ និង អាលុយមីញ៉ូមដែលសុទ្ធតែអាចធ្វើការកែច្នៃឡើងវិញបាន។




សំបកអាលុយមីញ៉ូមជាវត្ថុមួយដែលអាចធ្វើការកែច្នៃឡើងវិញបាន។

ដបភាគច្រើនត្រូវបានប្រមូលយកទៅរោងចក្រដើម្បីធ្វើការកែច្នៃឡើងវិញ។







ការដាក់កាកសំណល់ក្រដាសនៅដាច់ដោយឡែក ជាវិធីងាយស្រួលក្នុងការធ្វើកែច្នៃឡើងវិញ។

ការកែច្នៃសំណល់យកមកប្រើប្រាស់ឡើងវិញ គឺជាជោគជ័យធំមួយក្នុងការបន្ថយការបញ្ចេញកាកសំណល់ទៅក្នុងបរិស្ថាន។

# ចូលរួមទាំងអស់គ្នា



ការបង្ហាត់បង្រៀនក្មេងជំនាន់ក្រោយឱ្យយល់ដឹងពីសារៈសំ-ខាន់នៃការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវតាមគ្រឹះស្ថានសិក្សាគឺជាការអប់រំមួយដ៏ល្អ។



ការបណ្តុះស្មារតីកុមារឲ្យចេះបែងចែកសំណល់ទៅតាមប្រភេទដោយមានការចូលរួមពីអាណា-ព្យាបាល ជាការបង្ហាញនូវគំរូអនុវត្តល្អៗ។

ការកាត់បន្ថយកាកសំណល់គឺជាវិធីមួយដ៏មានប្រសិទ្ធភាព។ ការកែច្នៃកាកសំណល់ដោយធ្វើការប្រើប្រាស់ឡើងវិញ ការកែច្នៃ ឬការប្រើប្រាស់កាកសំណល់សម្រាប់បង្កើតថាមពលអគ្គិសនី អាចកាត់បន្ថយការប៉ះពាល់ដល់បរិស្ថានដែលបង្កឡើងដោយការផលិត ការប្រើប្រាស់ និងការបោះចោលផលិតផល។

រៀបចំដោយ:

គាំទ្រដោយ:

ឧបត្ថម្ភដោយ: